-ការិយាល័យនិមួយៗដឹកនាំដោយ ប្រធានមួយរូបនិងអនុប្រធានជា ជំនួយការ

-បណ្តាភារកិច្ចលំអិតតាមនាយកដ្ឋាននិមួយៗ ត្រូវកំណត់ដោយ ថ្នាក់ដឹកនាំនាយកដ្ឋានហើយត្រូវ បានឯកភាពពីថ្នាក់ដឹក នាំអគ្គនាយកដ្ឋាន ព្រះបរមរាជវាំង ។

មាត្រា ៣ : គ្រប់អង្គភាពចំណុះអគ្គនាយកដ្ឋាន ព្រះបរមរាជវាំង ត្រូវទទួលអនុវត្តតាមប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**គង់ សំអុល**

* * *

# II.ទីស្តីការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៩៤*

អនុក្រឹត្យលេខ ២៩ អនក្រ

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញតម្រូវការចាំបាច់ក្នុងការស្តារ និង កសាងប្រទេស

សំរេច

មាត្រា ១ : បង្កើតមេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ ដើម្បីជូនដល់សប្បុរជនកម្ពុជា ទាំងក្នុងប្រទេស និង ក្រៅប្រទេស ឬជនបរទេស

ជាបុគ្គល ឬ ជាសមូហភាពដែលបាន ធ្វើវិភាគទានជាថវិកា ឬសំភារៈក្នុងការរួមចំណែកស្ថាបនាប្រទេសជាតិ និង ទ្រទ្រង់សមរភូមិមុខ

មាត្រា ២ : មេដាយស្ថាបនាជាតិមាន ៣ ថ្នាក់គឺថ្នាក់លេខ ១ ពណ៌មាសថ្នាក់លេខ២ ពណ៌ប្រាក់ និង ថ្នាក់លេខ៣ ពណ៌សង្ហិន ។ លក្ខខ័ណ្ឌ សំរាប់ប្រគល់ជូន មេដាយ ស្ថាបនាជាតិមានដូចតទៅ :

១-សប្បុរសជនដែលបានធ្វើអំណោយជូន រដ្ឋជាថវិកាសំភារៈមានតំលៃលើសពីដប់ម៉ឺនដុល្លារអាមេរិក (US$100,000) ឡើងទៅត្រូវបានជូនមេដាស្ថាបនាជាតិជាតិថ្នាក់លេខ១ និងត្រូវបានរាជរដ្ឋាភិបាលស្នើសុំ ព្រះរាជយោបល់ដ៏ខ្ពង់ខ្ពស់នៃ ព្រះករុណាជាអម្ចាស់ជីវិតដ៏កល់លើត្បូង ដើម្បីទ្រង់ព្រះរាជទានគោរម្យងារ ជា « ឧកញ៉ា » ។

២-សប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋជា ថវិកាឬសំភារៈមានតំលៃចាប់ពីមួយម៉ឺនដុល្លាអាមេរិកដល់ដប់ម៉ឺនដុល្លារអាមេរិក (US$10,000 - US$100,000) ត្រូវ បានជូនមេដាយស្ថាបនាជាតិថ្នាក់លេខ១ ។

៣-សប្បុរសជនដែលបានធ្វើអំណោយ ជូនរដ្ឋជាថវិកា ឬសំភារៈតំលៃចាប់ពីប្រាំពាន់ដុល្លារអាមេរិកដល់មួយម៉ឺនដុល្លារ អាមេរិក ( US$ 5.000- US$10.000 ) ត្រូវបានជូនមេដាយ ស្ថាបនាជាតិ ថ្នាក់លេខ ២ ។

៤-សប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋជាថវិកា ឬសំភារៈមានតំលៃចាប់ពីមួយពាន់ដុល្លារអាមេរិកដល់ ប្រាំពាន់ដុល្លារអាមេរិក (US$1.000-US$5.000) ត្រូវបានជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ។

មេដាយស្ថាបនាជាតិ ត្រូវបានសំរេច ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ៣ : ប័ណ្ណស្ថាបនាជាតិសំរាប់ ជូនចំពោះសប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋជាថវិកា ឬ សំភារៈមានតំលៃចាប់ ពីប្រាំរយដុល្លារអាមេរិក ដល់មួយពាន់ដុល្លារអាមេរិក **( US$ 500 - US$ 1.000 )** ប័ណ្ណស្ថាបនា ជាតិត្រូវបានសំរេចដោយសេចក្តីសំរេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤** : គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និង ខេត្ត ក្រុង ក្រោយពេលបានទទួលអំណោយពីសប្បុរសជន ជាទឹកប្រាក់ឬ សំភារៈដូចមានចែងក្នុងមាត្រា ២ និង ៣ ត្រូវធ្វើសំណើមកទីស្តីការគណៈរដ្ឋមន្ត្រីដោយភ្ជាប់មកជាមួយនូវឈ្មោះ ម្ចាស់អំណោយទឹកប្រាក់ និង មុខសញ្ញា ដែលត្រូវប្រើប្រាស់អំណោយ នៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**មាត្រា ៥** : សហរដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ ខេត្ត ក្រុង ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពល្អ ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៤*

អនុក្រឹត្យលេខ ៥៦ អនក្រ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ខែ វិច្ឆិកា វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា